**ជនទេសន្តរប្រវេស ជនចំណាកស្រុក និងជនភៀសខ្លួន**

- ជនទេសន្តរប្រវេស ជនចំណាកស្រុក និងជនភៀសខ្លួន ជួបប្រទះនឹងហានិភ័យពិសេស ដោយសារពួកគេអាចត្រូវបានជាប់ឃុំនៅក្នុងជំរុំ និងនៅកន្លែងតាំងទីលំនៅ ឬរស់នៅក្នុងតំបន់ទីក្រុង ដែលមានលក្ខណៈចង្អៀតណែន ខ្វះអនាម័យ ហើយសេវាសុខភាពមានលក្ខណៈក្បត់ខ្សោយ ឬមិនអាចទៅដល់។ អ្នកដែលជាប់ឃុំនៅក្នុងមណ្ឌលឃុំឃាំងជនអន្តោប្រវេស និងកន្លែងផ្សេងៗទៀត ដែលជនទេសន្តរប្រវេស និងជនភៀសខ្លួន ត្រូវបានដកហូតសិទ្ធិសេរីភាពរបស់ខ្លួន មានហានិភ័យខ្ពស់។
- ជនទេសន្តរប្រវេស និងជនភៀសខ្លួន ជារឿយៗតែងតែជួបនឹងឧបសគ្គក្នុងការទទួលបានកិច្ចគាំពារសុខភាព រួមមាន របាំងភាសា និងវប្បធម៌ ការចំណាយ កង្វះលទ្ធភាពទទួលបានព័ត៌មាន ការរើសអើង និងការស្អប់ខ្ពើមជនបរទេស។ ជនទេសន្តរប្រវេស ដែលស្ថិតក្នុងស្ថានភាពមួយមិនទៀងទាត់ អាចមិនមានលទ្ធភាព ឬមិនមានបំណងទទួលបានសេវាគាំពារសុខភាព ឬផ្តល់ព័ត៌មានអំពីស្ថានភាពសុខភាពរបស់ខ្លួន ពីព្រោះពួកគេភ័យខ្លាច ឬប្រឈមនឹងការឃុំឃាំង ការនិរទេស ឬទោសទណ្ឌ ដោយសារតែឋានៈអន្តោប្រវេសន៍របស់ពួកគេ។
- រដ្ឋទាំងឡាយ គួរចាត់វិធានការជាក់លាក់ ដើម្បីបញ្ចូលជនទេសន្តរប្រវេស ជនចំណាកស្រុក និងជនភៀសខ្លួន ក្នុងគោលនយោបាយថ្នាក់ជាតិបង្ការទប់ស្កាត់ និងឆ្លើយតបនឹងជំងឺកូវីដ-១៩។ នេះគួរបញ្ចូលទាំងការធានាសិទ្ធិទទួលបានដោយស្មើភាពគ្នានូវព័ត៌មាន ការធ្វើតេស្ត និងកិច្ចគាំពារសុខភាពសម្រាប់ជនទេសន្តរប្រវេស ជនចំណាកស្រុក និងជនភៀសខ្លួនទាំងអស់ ដោយមិនគិតពីឋានៈរបស់ពួកគេ ក៏ដូចជាជញ្ជាំងការពារ ដើម្បីបំបែកសកម្មភាពអនុវត្តច្បាប់អន្តោប្រវេសន៍ ចេញពីសមត្ថភាពរបស់ជនទេសន្តរប្រវេស និងជនភៀសខ្លួន ក្នុងការទទួលបានសេវាសុខភាព ការចែកចាយស្បៀងអាហារ និងសេវាសំខាន់ៗផ្សេងទៀត។
- ការគាំទ្រពីអន្តរជាតិត្រូវការជាបន្ទាន់ ដើម្បីជួយប្រទេសម្ចាស់ផ្ទះ បង្កើនសេវាផ្សេងៗ - សម្រាប់ជនទេសន្តរប្រវេសន៍ ជនចំណាកស្រុក ជនភៀសខ្លួន និងសម្រាប់សហគមន៍មូលដ្ឋាន និងដើម្បីបញ្ចូលពួកគេក្នុងការរៀបចំបង្ការទប់ស្កាត់ និងឆ្លើយតបថ្នាក់ជាតិ។ ការខកខានមិនបានធ្វើបែបនេះ នឹងបង្កគ្រោះថ្នាក់ដល់សុខភាពដល់អ្នករាល់គ្នា - និងហានិភ័យខ្លាំងនឹងបញ្ហាអរិយភាព និងមាក់ងាយ។ វិធានការជាក់លាក់ គួរតែត្រូវបានអនុវត្ត ដើម្បីប្រឆាំងនឹងអរិយភាព និងការស្អប់ខ្ពើមជនបរទេស សំដៅទៅលើជនទេសន្តរប្រវេស ជនចំណាកស្រុក ឬជនភៀសខ្លួន។
- ការនេះ សំខាន់ចាំបាច់ផងដែរ ដែលការរឹតបន្តឹងការត្រួតពិនិត្យព្រំដែន ការរឹតត្បិតការធ្វើដំណើរ ឬការដាក់កម្រិតលើសេរីភាពក្នុងការដើរហើរ មិនរារាំងប្រជាជនដែលអាចភៀសខ្លួនចេញពីសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញ ឬអ្នកដែលអាចទទួលបានការការពារក្រោមច្បាប់សិទ្ធិមនុស្ស ពីការទទួលបានសុវត្ថិភាព និងការការពារឡើយ។ រដ្ឋទាំងឡាយ គួរពិចារណាដោះលែងជពីកន្លែងឃុំខ្លួនជនអន្តោប្រវេសន៍ និងផ្អាកជាបណ្តោះអាសន្នការបញ្ជូនដោយបង្ខំត្រឡប់ទៅវិញ ជាមធ្យោបាយមួយ ដើម្បីការពារទេសន្តរប្រវេសន៍ បុគ្គលិកអន្តោប្រវេសន៍ និងសង្គមទាំងមូល។
- សូមមើល<u>សេចក្តីណែនាំ៖ កូវីដ-១៩ និងសិទ្ធិរបស់ជនទេសន្តរប្រវេស</u> (ឯកសារ PDF)